**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៦៤
ចុះថ្ងៃទី០៦ ខែកម្ភៈ ឆ្នាំ២០០៤
**សាលដីកា**
លេខៈ១២២
ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធាន
២-លោក **ជីវ កេង** ជាចៅក្រម
៣-លោក **សោម សិរិវឌ្ឍ** ជាចៅក្រម
៤-លោក **គង់ ភីរុន** ជាចៅក្រម
៥-លោក **យូរ ឧត្តរា** ជាចៅក្រមរបាការណ៍

**ក្រឡាបញ្ជី**
-កញ្ញា **ធន់ វណ្ណធឿន**

**តំណាងមហាអយ្យការ**
-លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១៥៦(ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥៧៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ រវាងៈ

ដើមចោទ ឯកឧត្តម អ៊ឹង ហួត ចុងបណ្តឹងសាទុក្ខ អាយុ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរទីប្រឹក្សារាជរដ្ឋាភិបាល ទីលំនៅផ្ទះលេខ៤៩៩ ក្រុម ១៨ ភូមិបានអង្គាញ់ ឃុំព្រែកឯង ស្រុកគៀនស្វាយ ខេត្តកណ្តាល ។

មានមេធាវី លោក សែម ចិន្តា

និងចុងចម្លើយ លោក គង់ បូរិន្ទ ដើមបណ្តឹងសាទុក្ខអាយុ៣៤ឆ្នាំ ជាតិខ្មែរ មុខរបរ សិប្បកម្មឡឥដ្ឋ ទីលំនៅភូមិលេខ០១ សង្កាត់ច្រាំងចំរះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះដូ គង់ (ស) ម្តាយឈ្មោះ មួង ម៉ាលីស(ស) ប្រពន្ធឈ្មោះ រស់ សារៀម ។

អំពីវិវាទៈ ប្តឹងទារដីទំហំ៧២០០ម$^2$ និងទំហំ២៧៥ម×៣០ម

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៦៤ ចុះថ្ងៃទី០៦ខែកុម្ភៈឆ្នាំ២០០៤ របស់តុលាការកំពូល។

បានឃើញបណ្តឹងសាទុក្ខលេខ២០៩ ចុះថ្ងៃទី២៣ខែធ្នូ ឆ្នាំ២០០៣ របស់លោកគង់ បូរិន្ទ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥៦(ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២០-១២-២០០២ របស់ដើមចោទឯកឧត្តម អ៊ឹង ហួត បានប្តឹងទាមទារសិទ្ធិគ្រប់គ្រងដីទំហំ៧២០០ម² និងទំហំ២៧៥ម×៣០ម ពីឈ្មោះគង់ បូរិន្ទ ដោយសំអាងហេតុថា ដីនោះខ្លួនបានទិញពីឈ្មោះសៀ គីសូ ហើយសព្វថ្ងៃនេះ ខ្លួនបានដាក់ពាក្យស្នើសុំកាន់កាប់ និងប្រើប្រាស់ដី ធ្វើរួចហើយ ចុះថ្ងៃទី១៣-០១-១៩៩២ និងដីមួយឡូត៍ទៀតដែលស្ថិតនៅជាប់គ្នានោះខ្លួន(អ៊ឹង ហួត) ក៏បានដាក់ពាក្យស្នើសុំកាន់កាប់ និងប្រើប្រាស់រួចហើយដែរ ចុះថ្ងៃទី០១-០៤-១៩៩២ ហើយដីឡូត៍ទាំងពីរនោះ ពេលដែលខ្លួនបានទិញគឺមានសិប្បកម្មឡឥដ្ឋនេះមួយរួចហើយ ប៉ុន្តែក្រោយមកខ្លួនក៏បានជួលសិប្បកម្មឡឥដ្ឋនេះទៅឱ្យ ឈ្មោះគង់ បូរិន្ទ ជាចុងចម្លើយ ក្នុងតម្លៃ២០០ដុល្លាអាមេរិក (ពីរយដុល្លាអាមេរិក) ក្នុង១ខែ ស្រាប់តែនៅ ពេលដែលខ្លួនបានទាមទារយកដីនោះមកវិញ បែរជាភាគីចុងចម្លើយឈ្មោះគង់ បូរិន្ទ មិនព្រមចាកចេញប្រគល់ដីនោះមកវិញឡើយ ទើបខ្លួនដាក់ពាក្យបណ្តឹងមកតុលាការទាមទារសិទ្ធិគ្រប់គ្រងដី ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣០(ច) ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ឯកឧត្តមអ៊ឹង ហួត ចុះថ្ងៃទី២០-១២-២០០២ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ការផ្ទេរសិទ្ធិពីឯកឧត្តមអ៊ឹង ហួត ឱ្យលោកមេធាវីសែម ចិន្តា ជាតំណាងទុកជា ត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់ដីដែលមានទំហំ៧២០០ម៉ែត្រការ៉េ ដូចក្នុងលិខិតផ្ទេរសិទ្ធិប្រើប្រាស់កាន់កាប់ដីធ្លីមានបញ្ជាក់លេខ១១៩៧ ចុះថ្ងៃទី ០១-១០-២០០២ របស់ចៅសង្កាត់ច្រាំងចំរេះ២ និងទំហំ២៧៥ម៉ែត្រx ៣០ម៉ែត្រ ដូចក្នុងបង្កាន់ដៃស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ២៣១៦៦ ចុះថ្ងៃទី០៣-០៤-១៩៩២ របស់ការិយាល័យកសិកម្មស្រុកឫស្សីកែវ ស្ថិតនៅភូមិ១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ជាកម្មសិទ្ធិរបស់ឯកឧត្តម អ៊ឹង ហួត និងលោកជំទាវ អ៊ឹង ម៉ាលីសអ៊ីវន តទៅ ។

៤- បង្គាប់ឱ្យភាគីចុងចម្លើយលោកគង់ បូរិន្ទ រុះរើសំណង់របស់ខ្លួនដែលបានសង់បន្ថែម ព្រមទាំងសំភារៈផ្សេងៗ ដែលជារបស់ខ្លួនទៀតចេញពីដីនោះជាបន្ទាន់ បន្ទាប់ពីសាលក្រមនេះចូលជាស្ថាពរ រួចប្រគល់ដី និងសំណង់ចាស់ព្រមទាំងសំភារៈផ្សេងៗដែលជារបស់ដើមចោទជូនទៅភាគីដើមចោទគ្រប់គ្រងដូចដើមវិញ ។

៥- ចំពោះបណ្តឹងទាមទារថ្លៃសំណងផ្សេងៗ របស់ដើមចោទលើសពីនេះ ត្រូវបដិសេធចោល ។

៦-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧០០០រៀល ដែលដើមចោទបានបង់ទុកជាស្រេចតែនៅពេលសាលក្រមនេះចូលជាស្ថាពរ បង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួន៧០០០រៀល ទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រចំនួន១% លើតម្លៃជាក់ស្តែងដែលប្រាក់ពន្ធនោះត្រូវបង់ចូលថវិការដ្ឋចំនួន៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំង ប្រទេសចំនួន២០% ។

៧- សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី សម្រេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៦(ច) ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់លោកគង់ បូរិន្ទមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៣០(ច) ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៥៦(ឈ) ចុះថ្ងៃទី២២ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២២-០៧-២០០៣ របស់ឈ្មោះគង់ បូរិន្ទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៣០(ច) ចុះថ្ងៃទី០៣-០៦-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣,០០០រៀល ដែលដើមចោទបានបង់ទុករួចហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊ីងចំនួន២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀលចំណាយលើការប្រគល់ដីកាកោះចំនួន៥.០០០រៀល និងអាជ្ញាធរតុលាការចំនួន៥.០០០រៀល ។ នៅពេលសាលដីកានេះ ចូលជាស្ថាពរ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់១៣០០០រៀល ទៅដើមចោទវិញ ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧-១០-២០០៣ ចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២-១០-២០០៣ ចំពោះមុខមេធាវីតំណាងដើមចោទ កំបាំងមុខចុងចម្លើយ ។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២០៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់លោកគង់ បូរិន្ទ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥៦(ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើសាលដីការទាំងមូល ។

បានឃើញសារណាបំភ្លឺរបស់ឯកឧត្តម អ៊ឹង ហួត ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០០៤

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា៖

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ១៥៦(ឈ)ចុះថ្ងៃទី២២ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឯកឧត្តមអ៊ឹង ហួត ឆ្លើយថា រឿងក្តីនេះកើតឡើងមកតាំងពីឆ្នាំ១៩៩៧ មក គឺនៅម្តុំគីឡូម៉ែត្រលេខ៧ ដោយដីនេះខ្លួនបានទិញតាំងពីឆ្នាំ១៩៩២ មកម្ល៉េះ បន្ទាប់មកក្នុងឆ្នាំ១៩៩២ នេះដែរខ្លួនក៏បានសុំបើកសិប្បកម្មឡឥដ្ឋមួយ មានច្បាប់ទម្លាប់ត្រឹមត្រូវ។ ក្រោយមកខ្លួនក៏បានជួលឱ្យគេ បាន៣០០ដុល្លារ ក្នុង១ខែ តែគេពុំបានគោរពតាមកិច្ចសន្យាសោះ ព្រោះគេបានជីកស្រះទឹកមួយនៅខាង ក្រោយនៃដី ដោយគ្មានការព្រមព្រៀងពីខ្លួន ខ្លួនក៏សម្រេចចិត្តឈប់ជួលឱ្យគេទៀតទៅ។ ក្រោយមកទៀត ខ្លួនក៏បានជួលឱ្យប្អូនថ្លៃរបស់ខ្លួន ឈ្មោះគង់ បូរិន្ទ វិញ តែតម្លៃប្រាក់ឈ្នួល២០០ដុល្លារ ក្នុង១ខែ ប៉ុន្តែតាំង ពីជួលនេះមក គេបានបង់តម្លៃប្រាក់ឈ្នួល ឱ្យខ្លួន បានតែ ២ខែ តែប៉ុណ្ណោះ ។

ស្រាប់តែនៅពេលដែលខ្លួនបានទាមទារយកដីនោះមកវិញឈ្មោះគង់ បូរិន្ទ នេះពុំព្រមប្រគល់ដី នេះ មកឱ្យខ្លួនវិញទេ កន្លងមកខ្លួនក៏បានប្រាប់គេដែរថា នៅពេលដែលខ្លួនលក់ដីនេះបានហើយខ្លួននឹង ប្រគល់ប្រាក់ឱ្យខ្លះ ប៉ុន្តែឈ្មោះគង់ បូរិន្ទ នេះនៅតែពុំព្រមទៀត ដូច្នេះខ្លួននៅតែប្រកាន់ជំហរដដែល គឺ ខ្លួនទាមទារ សំណងរបស់ខ្លួនមកវិញ ហើយខ្លួនមិនអាចឱ្យប្រាក់បន្ថែមទៅគេទៀតបានទេ ។

សូមលោកតុលាការកំពូល មេត្តាជួយវិនិច្ឆ័យតាមការគួរ ។

ខ្លួនសូមបញ្ជាក់បន្ថែមទៀតថា គេបាននិយាយគំរាមកំហែងថា គេមិនឱ្យខ្លួន និងគ្រួសាររបស់ ខ្លួន មានសេចក្តីសុខឡើយ ។

បានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីលោកសែម ចិន្តា ការពារឱ្យដើមចោទបញ្ជាក់ថា៖

សាលាឧទ្ធរណ៍ បានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ ម៉្យាងទៀតកូនក្តីរបស់ ខ្លួនពិតជាបានជួលសិប្បកម្មឡឥដ្ឋនេះទៅឱ្យឈ្មោះគង់ បូរិន្ទ មែនព្រោះមានសាក្សីដឹងឮត្រឹមត្រូវប្រាកដ មែន។ ហើយឈ្មោះគង់ បុរិន្ទ នេះតាំងពីជួលមកគេបានធ្វើអ្វីៗនៅលើដីនេះ សុទ្ធតែពុំមានឯកភាពពីឯក ឧត្តមអ៊ឹង ហួត ជាម្ចាស់ទេ ។ ចំពោះសំណងដែលទាមទារដោយសារថា បានរស់នៅលើដីនោះ គឺពិតជាពុំ ត្រឹមត្រូវទេ និងការទាមទារថ្លៃចំពោះឡឥដ្ឋនៅលើដីនោះ គឺពិតជាពុំត្រឹមត្រូវទេ និងការទាមទារថ្លៃចំពោះ ឡឥដ្ឋនៅលើដីនេះពី ឯកឧត្តមអ៊ឹង ហួត នៅសាលាឧទ្ធរណ៍ក៏ពុំបានសម្រេចឱ្យដែរ ។ ចំពោះការបង់ប្រាក់ ថ្លៃឈ្នួលនេះ គេពុំបានបង់ឲ្យកូនក្តីខ្លួន តាមការកំណត់ដែរ គឺបានបង់តែ២ខែ ប៉ុណ្ណោះ ។

-សូមទាមទារដី និងឡឥដ្ឋ ជារបស់កូនក្តីខ្លួនមកវិញ ។

-សូមទាមទារប្រាក់ថ្លៃឈ្នួល ដែលភាគីចុងចម្លើយ ពុំបានបង់ឲ្យកូនក្តីខ្លួនរហូតមក និងសូមឲ្យភាគី ចុងចម្លើយរុះរើចេញ បើមានការសាងសង់ថ្មីនៅលើដី ដែលគ្មានការយល់ព្រមពីកូនរបស់ខ្លួន ។

-សូមលោក តុលាការមេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដើមចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២០៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះគង់ បូរិន្ទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ កមជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលចុងចម្លើយ សុំឲ្យដើមចោទចេញសោហ៊ុយឲ្យខ្លួនចំនួន៤៧២២៥ដុល្លារអាមេរិក ជាថ្នូរទៅនឹងការកែលំអឡូឥដ្ឋ ដែលមានស្រាប់នោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា ដើមចោទបានអនុញ្ញាតឲ្យចុងចម្លើយត្រឹមតែស្នាក់នៅ និងធ្វើអាជីវកម្មលើឡូឥដ្ឋ ដែលមានស្រាប់តែប៉ុណ្ណោះ ហើយម្យ៉ាងទៀត ការចេញសោហ៊ុយកែលំអរឡូឥដ្ឋនេះ ក៏ពុំមានការសន្យា ឬការយល់ព្រមអ្វីពីដើមចោទ ដែលតម្រូវឲ្យដើមចោទ មានកាតព្វកិច្ចឡើយ ។ ម្យ៉ាងទៀតចុងចម្លើយ ក៏មិនបានជូនភស្តុតាង ស្តីអំពីការចំណាយនេះសម្រាប់ជាមូលដ្ឋានក្នុងការគិតគូដែរ ។

-យល់ឃើញថា ពុំមានភស្តុតាងណា បញ្ជាក់ថា ដើមចោទបានឲ្យដីទំនាស់ដាច់ទៅចុងចម្លើយទេ។

-យល់ឃើញថា លោកគង់ បូរិន្ទ បានទទួលលិខិតបង្គាប់ឲ្យធ្វើសារណា និងដីកាកោះឲ្យមកចូលរួម នាសវនាការនេះហើយ ប៉ុន្តែលោកពុំបានធ្វើសារណា និងពុំបានមកចូលរួមនាសវនាការនេះទេ ហើយបានសុំពន្យាពេលសវនាការនេះ ទៅថ្ងៃក្រោយ ប៉ុន្តែពុំមានមូលហេតុគ្រប់គ្រាន់ ដែលអាចពន្យាពេលឲ្យបានទេ ។ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៥៦(ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ២០៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះគង់ បូរិន្ទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ១៥៦(ឈ) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។ x

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០រៀល ដែលដើមចោទបានបង់គឺ

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល

-បង្គាប់ឱ្យចុងចម្លើយសងប្រាក់១៩០០០រៀល ទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយបង់ ពន្ធសមាមាត្រ តាមការកំណត់របស់តុលាការក្រុងភ្នំពេញ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤